# ឯកសារទស្សនទាន សម្រាប់វេទិការៀនសូត្រស្តីពី

## ការងារអភិវឌ្ឍន៍ និងវឌ្ឍនភាពសម្រាប់អង្គការថ្នាក់ក្រោមជាតិ

ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ នៅអង្គការហ្វារពន្លឺសិល្បៈ ទីរួមខេត្តបាត់ដំបង

## បុព្វកថា

ស្របតាមសម័យបច្ចេកវិទ្យាទំនើប និងដំណើររីកចម្រើនផ្លាស់ប្តូរយ៉ាងឆាប់រហ័ស នូវដំណើរនៃការអភិវឌ្ឍ កម្ពុជាក៏ទទួលរងនូវប្រែប្រួលទាំងនេះផងដែរ។ ជាក់ស្តែង យើងអាចសង្កេតឃើញថា ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសកម្ពុជាមានការវិវត្តយ៉ាងឆាប់រហ័ស បន្ទាប់ពីមានកំណែទម្រង់សេដ្ឋកិច្ច និងនយោបាយ។ ហើយដំណើរការនេះ នៅតែបន្តប្រែប្រួលទាំងថ្នាក់សកល ថ្នាក់តំបន់ និងថ្នាក់ជាតិ រួមមានការរៀបចំផែនការថ្មីសម្រាប់របៀបវារៈក្នុងការអភិវឌ្ឍឆ្នាំ២០៣០ (គោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព) ផែនការអនុវត្តការងារគណនេយ្យភាពសង្គម ក៏ដូចជាកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជំហានទី២។ ផ្ទុយទៅវិញ យើងសង្កេតឃើញថាថ្មីៗនេះ បរិយាកាសសង្គមកម្ពុជាសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក៏ដូចជាលំហាបរិយាកាសអង្គការសង្គមស៊ីវិលត្រូវបានរួមតូចចង្អៀត តាមរយៈការអនុម័តច្បាប់ដ៏ចំរូងចំរាស់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងច្បាប់មួយចំនួនទៀតដូចជាច្បាប់ស្តីពីសហជីពជាដើម។ ម្យ៉ាងវិញទៀត បរិបទសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់អង្គការសង្គមស៊ីវិលក៏មានការធ្លាក់ចុះ។ ដូច្នេះហើយ អង្គការសង្គមស៊ីវិល គួររៀបចំយន្តការ និងគំនិតផ្តួចផ្តើមថ្មីៗ ដើម្បីសកម្មភាពនិរន្តរភាពគម្រោង និងហិរញ្ញវត្ថុ ក៏ដូចជាឆ្លើយតបតាមនិន្នាការនៃការផ្លាស់ប្តូរប្រែប្រួល និងបរិបទអភិវឌ្ឍន៍ទាំងនេះ។

អាស្រ័យហេតុនេះ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ជាអង្គការសមាជិកភាព ដែលត្រូវបានបង្កើតឡើងតាំងពីទសវត្សរ៍ឆ្នាំ១៩៩០ និងមានតួនាទីក្នុងការជួយសម្របសម្រួល និងកសាងសមត្ថភាពសម្រាប់អង្គការសមាជិក និងដៃគូអភិវឌ្ឍផ្សេងទៀត។ ម៉្យាងទៀត អង្គការ CCC ធ្លាប់ចូលរួមសហការជាមួយអង្គការសមាជិក និងបណ្តាញអង្គការថ្នាក់ខេត្ត ក្នុងការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ជាអាទិ៍ធ្លាប់មានកិច្ចសហការជាមួយអង្គការមនុស្សចាស់កម្ពុជា ជាដើម។ យោងតាមតម្រូវការ សារតា និងកិច្ចពិភាក្សាកន្លងមក អង្គការ CCC រួមជាមួយសមាគម ហ្វារពន្លឺសិល្បៈ និងអង្គការមនុស្សចាស់កម្ពុជា បានផ្តួចផ្តើមសហការរៀបចំវេទិការៀនសូត្រថ្នាក់តំបន់មួយ ស្តីពី **ការងារអភិវឌ្ឍន៍ និងវឌ្ឍនភាពសម្រាប់អង្គការថ្នាក់ក្រោមជាតិ** ដែលនឹងប្រព្រឹត្តិទៅនា **ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦** នៅទីរួមខេត្តបាត់ដំបង_ ដែលមានសមាសភាពចូលរួមពីថ្នាក់ដឹកនាំអង្គការ និងមន្ត្រីកម្មវិធី និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដែលមានចំនួនសរុបប្រមាណជាង ៧០-៨០នាក់។

## គោលបំណងវេទិការៀនសូត្រ

វេទិការៀនសូត្រនេះ មានគោលបំណងដើម្បីៈ

- ចែករំលែកនូវប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតម្លៃគម្រោងតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប
- ពិភាក្សាលើបរិបទអភិវឌ្ឍថ្មីៗ និងបញ្ហាប្រឈមសម្រាប់អង្គការសង្គមស៊ីវិល
- ស្វែងរកយន្តការសម្រាប់ឆ្លើយតបលើបញ្ហាប្រឈម និងនិន្នាការនៃការអភិវឌ្ឍន៍សម្រាប់និរន្តរភាពគម្រោង និងហិរញ្ញវត្ថុ។

## សមាសភាពចូលរួម និងទីកន្លែង

វេទិការសម្រាប់ការរៀនសូត្រនេះ នឹងរៀបចំឡើងនៅសមាគមហ្វារពន្លឺសិល្បៈ ទីតាំងនៅភូមិអញ្ចាញ សង្កាត់អូរចា ទីរួមខេត្តបាត់ដំបង។

សមាសភាពចូលរួមក្នុងវេទិកានេះមានប្រមាណ៧០-៨០នាក់ ដែលរួមមានតំណាងអង្គការសមាគម ដែលសមាជិកភាពរបស់អង្គការ CCC សមាជិកអង្គការបណ្ដាញថ្នាក់ខេត្ត និងអង្គការដៃគូអភិវឌ្ឍផ្សេងទៀត ដែលអញ្ជើញមកពីខេត្តបាត់ដំបង សៀមរាប បន្ទាយមានជ័យ ឧត្តមានជ័យ និងខេត្តពោធិ៍សាត់។

## លទ្ធផលរំពឹងទុក

- អង្គការចូលរួមមកពីខេត្តនៅតំបន់ពាយ័ព្យមានការយល់ដឹងពីការងារបណ្ដាញ ព្រមទាំងភ្ជាប់បណ្ដាញទំនាក់ទំនងអោយកាន់តែប្រសើរ។
- អ្នកចូលរួមមានការយល់ដឹងពីប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសម្រាប់យកទៅប្រើប្រាស់ក្នុងកម្មវិធី ស្របតាមសម័យបច្ចេកវិទ្យាទំនើប។
- ការវិវត្តថ្មីៗ របស់ថ្នាក់ជាតិ និងថ្នាក់តំបន់ និងបញ្ហាប្រឈមសម្រាប់អង្គការសង្គមស៊ីវិលត្រូវបានចែករំលែកយ៉ាងទូលំទូលាយ។
- អ្នកចូលរួមបង្កើតបានគំនិតផ្ដួចផ្ដើម និងយន្តការផ្សេងៗ ដើម្បីឆ្លើយតបតាមរបត់ប្រែប្រួលសង្គម និងការអភិវឌ្ឍ។

## របៀបវារៈ

| ពេលវេលា | កម្មវិធី | អ្នកសម្របសម្រួល |
|---|---|---|
| 7:30-8:00 | **ការចុះឈ្មោះចូលរួមភ្ញៀវកិត្តិយល និងគណៈអធិបតី** | អង្គការមនុស្សចាស់កម្ពុជា |
| 8:00-8:15 | **គោរពភ្លេងជាតិ និងបង្ហាញពីកម្មវិធី** | **លោក យួន ចាន់រស្មី**<br>អ្នកកាន់កម្មវិធីសមាគមហ្វារពន្លឺសិល្បៈ |
| 8:15-8:35 | **-មតិស្វាគមន៍សម្រាប់វេទិការៀនសូត្រ**<br><br>**-សុន្ទរកថាបើកកម្មវិធីបើកកម្មវិធី** | **-លោក សៀង សារឿន**<br>នាយកប្រតិបត្តិ _អង្គការ CCC<br>**-លោក Eric Regualt**<br>នាយកប្រតិបត្តិ _សមាគមហ្វារពន្លឺសិល្បៈ |
| 8:35-9:35 | **និន្នាការនៃដំណើរអភិវឌ្ឍថ្មីៗពាក់ពន្ធ័នឹងអង្គការសង្គមស៊ីវិល**<br>- និន្នាការ និងផែនការអភិវឌ្ឍប្រកបដោយនិរន្តរភាព នៅថ្នាក់សកល និងថ្នាក់ជាតិ។<br>- ផែនការ និងយន្តការសម្រាប់ការងារអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ និងគណនេយ្យភាពសង្គម។<br>- បំរែបំរួលនៃហិរញ្ញប្បទាន សំរាប់ការអភិវឌ្ឍន៍<br><br>**សំនួរ និងចម្លើយ** | **-លោក សៀង សារឿន**<br>នាយកប្រតិបត្តិ_អង្គការ CCC<br><br>**-លោក ស៊ី ឈឿប**<br>អ្នកសម្របសម្រួលគម្រោង_អង្គការVSG<br>**-លោកស្រី សេរីណា លីលីវ៉ាយ**<br>ទីប្រឹក្សាផ្នែកទំនួលខុសត្រូវសាជីវកម្មសង្គម_អង្គការ CCC |
| 9:35- 10:35 | **ពិភាក្សាតុកាហ្វេលើបញ្ហាប្រឈម យន្តការ និងគំនិតផ្តួតផ្តើម**<br>- អភិបាលកិច្ចស្ថាប័ន<br>- ការអភិវឌ្ឍកម្មវិធី<br>- ហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍ<br>- ការឆ្លើយតបស្ថានភាពនៃការអវិឌ្ឍន៍<br><br>**បទបង្ហាញតាមក្រុម និងសំនួរ-ចម្លើយ** | **លោក ណាម មុនី**<br>ប្រធានហិរញ្ញវត្ថុ និងរដ្ឋបាល_សមាគមហ្វារពន្លឺសិល្បៈ |
| 10:35- 10:50 | សំរាកអាហារសំរ៉ន់ | |
| 10:50 -12:00 | **គំនិតផ្តួចផ្តើមឆ្លើយតបសម្រាប់អភិបាលកិច្ចស្ថាប័ន និងប្រសិទ្ធភាពគម្រោង**<br>- ប្រព័ន្ធអភិបាលកិច្ចសម្រាប់អង្គការសង្គមស៊ីវិល និងគោលការណ៍ណែនាំសម្រាប់អង្គការសហគមមូលដ្ឋាន<br>- យុទ្ធសាស្ត្រអភិវឌ្ឍកម្មវិធីផ្អែកលើសិទ្ធិមនុស្ស<br>- ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសំរាប់កម្មវិធី តាម | **-លោក ឈន វឌ្ឍនៈ**<br>អ្នកគ្រងគ្រងប្រព័ន្ធវិញ្ញាបនបត្រ GPP_អង្គការ CCC<br><br>**-លោកបណ្ឌិត ចាន់ វិបុល**<br>ទីប្រឹក្សាឯករាជ្យ |

| ពេលវេលា | កម្មវិធី | អ្នកសម្របសម្រួល |
| --- | --- | --- |
| | បែបបច្ចេកវិទ្យាទំនើប។<br>**យោបល់បន្ថែមពីតំណាងអង្គការតាមខេត្ត/ក្រុង ស្តីពីបទពិសោធន៍សម្រាប់ប្រព័ន្ធវិញ្ញាបនប័ត្រ ការងារបណ្តាញ និងសមាជិកភាព និង ការងារគម្រោង/កម្មវិធី**<br>**សំនួរ និងចម្លើយ** | **-លោក សៀង ទីប៉ូ**<br>ប្រធានផ្នែកកសាងសមត្ថភាព និងការរៀនសូត្រ_អង្គការ CCC |
| 12:00 – 1:30 | សម្រាកអាហារថ្ងៃត្រង់រួមគ្នា | |
| 1:30– 3:00 | **កិច្ចពិភាក្សា៖ និរន្តរភាពហិរញ្ញវត្ថុ និងការកៀរគរដៃគូ**<br>- គំនិតផ្តួចផ្តើមអំពីមូលនិធិសំរាប់អង្គការសង្គមស៊ីវិល<br>- ការទទួលខុសត្រូវផ្នែកសង្គមសម្រាប់ផ្នែកសាជីវកម្ម និងធនធាន<br>**ករណីសិក្សា៖**<br>- ការកៀគរធនធានហិរញ្ញវត្ថុសំរាប់សមាគមហ្វារពន្លឺសិល្បៈ<br>- គំនិតផ្តួចផ្តើម ភាពជាដៃគូពហុភាគីលើកម្មវិធី "ការគាំទ្រមនុស្សចាស់នៅកម្ពុជា"<br>**សំនួរ និងចម្លើយ** | **-លោក សៀង សារឿន**<br>នាយកប្រតិបត្តិ_ អង្គការ CCC<br>**-លោកស្រី សេរីណា លីលីវ៉ាយ**<br>ទីប្រឹក្សាផ្នែកទំនួលខុសត្រូវសាជីវកម្មសង្គម_អង្គការ CCC<br>**-លោក ហួត ដារា**<br>នាយកប្រតិបត្តិសហគ្រាសសង្គមហ្វារសៀមរាប_និង **លោក ណាម មុនី** ប្រធានហិរញ្ញវត្ថុ និងរដ្ឋបាល_សមាគមហ្វារពន្លឺសិល្បៈ<br>**-លោក ទុំ វីរ៉ា**<br>នាយកអង្គការមនុស្សចាស់កម្ពុជា |
| 3:00– 3:15 | សម្រាកអាហារសម្រន់ | |
| 3:15-4:15 | **គន្លឹះសំខាន់ៗ និងយន្តការបន្ត**<br>- យន្តការសំខាន់ និងឪកាសសម្រាប់ដំណើរការរួមបន្តទៅមុខ<br>- ពិភាក្សាលើយន្តការបន្ត ឬសកម្មភាពតាមខេត្តនីមួយៗ | **លោក ទុំ វីរ៉ា**<br>នាយកអង្គការមនុស្សចាស់កម្ពុជា<br>តំណាងក្រុម |
| 4:15-4:30 | **សរុប និងបិទកម្មវិធី** | **លោក សៀង សារឿន**<br>នាយកប្រតិបត្តិអង្គការ CCC |

**សំគាល់៖** អ្នករៀបចំកម្មវិធីសូមរក្សាសិទ្ធិក្នុងការកែប្រែរបៀបវារៈក្នុងករណីចាំបាច់។ (សូមមេត្តាទំនាក់ទំនងមកអ្នករៀបចំកម្មវិធីមុនសម្រាប់អង្គការ ដែលត្រូវការតុសម្រាប់ដាក់តាំងពិព័ណ៌សមិទ្ធផល និងទស្សនាការសម្តែងសៀកដោយឥតគិតថ្លៃ)។